**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## និរាករណ៍អនុក្រឹត្យ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យ ស្តីពីការធ្វើអនុបយោគផ្ទៃដីក្នុងតំបន់ការពារធម្មជាតិ ក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
- យោងលិខិតលេខ ១៤៧១ សជណ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

## **សម្រេច**

**មាត្រា ១.-**

១-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ **២០៥ អនក្រ.បក** ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ លើផ្ទៃដីទំហំ **៤.១៦០ (បួនពាន់មួយរយហុកសិប) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រេច ភូមិសាស្ត្រខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុន **កសិកម្មខ្មែរអង្គរ ខូអិលធីឌី (KASEKAM KHMER ANGKOR CO., Ltd)** ។

២-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ **៩១ អនក្រ.បក** ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម លើផ្ទៃដីទំហំ **៥.៥៥៤ (ប្រាំពាន់ប្រាំរយហាសិបប្រាំបួន) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ភូមិសាស្ត្រខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុន **អិល.ខេ.អិល ខនស្ត្រាក់សិន ខូអិលធីឌី (L.K.L CONSTRUCTION CO., LTD)** ។

**៣**-ត្រូវទុកជានិរាករណ៍នូវចំណុច **"គ"** នៅក្នុង **មាត្រា ១** នៃអនុក្រឹត្យលេខ **១២៨ អនក្រ.បក** ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ដំណាំកៅស៊ូ ដាំដំណាំកសិ-ឧស្សាហកម្ម និងដំណាំកសិកម្មលើផ្ទៃដីទំហំ **៥.០០០ (ប្រាំពាន់) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រស្រុកកែវសីមា ខេត្តមណ្ឌលគិរី របស់ក្រុមហ៊ុន **ឫទ្ធី គិរី សីមា** និងទុកជានិរាករណ៍នូវអនុក្រឹត្យលេខ **១២០ អនក្រ.បក** ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៥.០០០ (ប្រាំពាន់) ហិកតា** ស្ថិតក្នុងដែនជម្រកសត្វព្រៃស្នួល ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

**៤**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **JIANKING (Cambodia) International Investment Co., Ltd** លើផ្ទៃដីទំហំ **៨.៥៦៨ (ប្រាំបីពាន់ប្រាំរយហុកសិបប្រាំបី) ហិកតា** ក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គិរីរម្យ"** ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចខាងក្រោម៖

- អនុក្រឹត្យលេខ **០៣ អនក្រ.បក** ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- អនុក្រឹត្យលេខ **៨៣ អនក្រ.បក** ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៨.៥៦៨ (ប្រាំបីពាន់ប្រាំរយហុកសិបប្រាំបី) ហិកតា** ក្នុងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គិរីរម្យ"** ស្ថិតក្នុងភូមិសាស្ត្រ ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ។

**៥**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យលេខ **២១៧ អនក្រ.បក** ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **ស្រីបញ្ញា អភិវឌ្ឍន៍ ខូអិលធីឌី** លើផ្ទៃដីទំហំ **៥៨៨ (ប្រាំរយប៉ែតសិបប្រាំបី) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ ក្នុងភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តកំពង់ធំ។

**៦**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **ឃុន សៀ អ៊ឹមផត អិចផត** លើផ្ទៃដីទំហំ **៨.២០០ (ប្រាំបីពាន់ពីររយ) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ដូចខាងក្រោម៖

- អនុក្រឹត្យលេខ **៧៨ អនក្រ.បក** ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- អនុក្រឹត្យលេខ **១២៥ អនក្រ.បក** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ស្តីពីការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.២០០ (ប្រាំបីពាន់ពីររយ) ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តឧត្តរមានជ័យ។

**៧**-ត្រូវទុកជានិរាករណ៍នូវអនុក្រឹត្យនានា សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍របស់ក្រុមហ៊ុន **BSC Import Export Co., Ltd** លើផ្ទៃដីទំហំ **៤.៥៥៧ (បួនពាន់ប្រាំរយហាសិបប្រាំពីរ) ហិកតា**

ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ភូមិសាស្ត្រស្រុកភ្នំព្រឹក និងស្រុកកំរៀង ខេត្តបាត់ដំបង ដូចខាងក្រោម៖

- អនុក្រឹត្យលេខ **៩០ អនក្រ.បក** ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១២ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព
- អនុក្រឹត្យលេខ **១២៧ អនក្រ.បក** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៤.៥៥៧ **(បួនពាន់ប្រាំរយហាសិបប្រាំពីរ) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃរនាមដូនសំ ក្នុងភូមិសាស្ត្រស្រុកភ្នំព្រឹក និងស្រុកកំរៀង ខេត្តបាត់ដំបង។

**មាត្រា ២.-**

ផ្ទៃដីដែលគ្របដណ្តប់ដោយបណ្តាអនុក្រឹត្យដែលត្រូវបាននិរាករណ៍ ដូចមានចែងក្នុង **មាត្រា ១** នៃអនុក្រឹត្យនេះ ត្រូវដាក់បញ្ចូលជាដីដែនជម្រកសត្វព្រៃភ្នំព្រេច ដែនជម្រកសត្វព្រៃភ្នំណាមលៀរ ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ដែនជម្រកសត្វព្រៃបឹងពែរ និងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ **"គីរីរម្យ"** ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលខេត្តមណ្ឌលគិរី ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ